ក្រសួងអប់រំ យុវជន និងកីឡា

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# ការវិវត្តនៃប្រព័ន្ធគ្រប់គ្រងដីធ្លីនៅកម្ពុជា

# (Evolution of Land Management System in Cambodia)

ហាប់ ផល្លី

ខែកញ្ញា ឆ្នាំ២០០៩

# មាតិកា

- ប្រវត្តិកម្មសិទ្ធិដីធ្លីនៅកម្ពុជា
- ការគ្រប់គ្រងដីធ្លីនៅក្រោយឆ្នាំ១៩៧៩
- ឯកជនភាវូបនីយកម្មនៃដីធ្លីនៅឆ្នាំ១៩៨៩
- គោលដៅនៃការគ្រប់គ្រងដីធ្លី
- នានាភាពនៃបញ្ហាអំពីដីធ្លី និងយន្តការដោះស្រាយ
- សេចក្តីសន្និដ្ឋាន

# ប្រវត្តិកម្មសិទ្ធិដីធ្លីនៅកម្ពុជា (១)

- សម័យមុនអាណានិគមនិយមបារាំង

-ដីធ្លីទាំងអស់ជារបស់ព្រះមហាក្សត្រ ។

-ប្រជាពលរដ្ឋមានសិទ្ធិកាន់កាប់ ប្រើប្រាស់ បន្តមតិក ។

-ជាទូទៅដីចំនួនតែពី១-៣ហិកតាត្រូវបានប្រើប្រាស់ចំពោះគ្រួសារនីមួយៗ ។

-ការបោះបង់ដីចំនួន៣ឆ្នាំនាំទៅរកការបាត់បង់សិទ្ធិភោគៈ ។

-គ្មានពន្ធដីទេ តែមានតែពន្ធក្នុងទម្រង់ជាសួយសារអាករវិញ ។

-ការរំលោភសិទ្ធិលើដីធ្លីពីសំណាក់អ្នកមានអំណាចក៏ត្រូវបានដាក់ទណ្ឌកម្ម ។

# ប្រវត្តិកម្មសិទ្ធិដីធ្លីនៅកម្ពុជា (២)

- **សម័យអាណានិគមនិយមបារាំង (១៨៦៣_១៩៥៣)**

-ថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ព្រះមហាក្សត្រនរោត្តមបានចុះហត្ថលេខាដាក់កម្ពុជានៅក្រោមអាណាព្យាបាលរបស់បារាំង ដែលគេស្គាល់ថាជាសម័យអាណានិគមនិយម ។

-ព្រះមហាក្សត្រលែងជាអ្នកដែលមានសិទ្ធិអំណាចធ្វើជាម្ចាស់ដីធ្លីទៀតហើយ ។

-ក្រមរដ្ឋប្បវេណីត្រូវបានអនុម័តនៅឆ្នាំ១៩២0 កំណត់ពីកម្មសិទ្ធិ និងសិទ្ធិភោគៈជាដើម ។

-មានការប៉ុនប៉ងបង្កើតប្រព័ន្ធអភិរក្សសុរិយោដីមជ្ឈការទូទាំងប្រទេស ប៉ុន្តែបរាជ័យ ។

-មិនមានការិយាល័យអភិរក្សសុរិយោដីនៅទូទាំងប្រទេសទេ ។

# ប្រវត្តិកម្មសិទ្ធិដីធ្លីនៅកម្ពុជា (៣)

- របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥_១៩៧៩)

  -ប្រព័ន្ធច្បាប់ត្រូវបានបំផ្លាញខ្ទេចខ្ទីគ្មានសល់។

  -កម្មសិទ្ធិឯកជនត្រូវបានលុបបំបាត់។

  -ឯកសារនានាពាក់ព័ន្ធនឹងដីធ្លីត្រូវបានបំផ្លាញចោល។

  -មន្ត្រីសុរិយោដីស្ទើរតែទាំងអស់ត្រូវបានកាប់សម្លាប់។

  -ជាទូទៅ មនុស្សរស់នៅដូចជាទាសករ។

# ការគ្រប់គ្រងដីធ្លីនៅក្រោយឆ្នាំ១៩៧៩

- ការបង្កើតនាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម ដែលឋិតក្រោមក្រសួងកសិកម្ម (១៩៧៩)។
- ការបង្កើតក្រុមសាមគ្គីបង្កបង្កើនផល

  -ក្រុមសាមគ្គីប្រភេទទី១

  -ក្រុមសាមគ្គីប្រភេទទី២

  -ក្រុមសាមគ្គីប្រភេទទី៣
- ការចុះខ្សោយនៃការអនុវត្តគោលនយោបាយក្រុមសាមគ្គីបង្កបង្កើនផល

# សកម្មភាព១

១ ហេតុអ្វីបានជារដ្ឋាភិបាលត្រូវការបង្កើតក្រុមសាមគ្គីបង្កបង្កើនផល នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ នៅឆ្នាំ១៩៧៩?

២ ហេតុអ្វីបានជាមានការចុះខ្សោយនៃការអនុវត្តគោលនយោបាយក្រុមសាមគ្គីបង្កបង្កើនផល?

# ឯកជនភាវូបនីយកម្មនៃដីធ្លីនៅឆ្នាំ១៩៨៩ (១)

- ខែមេសា ឆ្នាំ១៩៨៩ សន្និបាទតំណាងកម្មាភិបាលទូទាំងប្រទេសលើកទី២ បានចេញសេចក្តីសម្រេចចិត្តចំនួន៥៖

  -សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី

  -សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយចំពោះកសិកម្ម

  -សេចក្តីសម្រេចចិត្តស្តីពីការប្រកបរបរអាជីវកម្ម ផលិតកម្មតាមរបៀបវេរប្រវ៉ាស់ដៃ

  -សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយចំពោះផលិតកម្ម អាជីវកម្មរូបភាពសិប្បកម្ម-ឧស្សាហកម្មតូចៗ

  -សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយចំពោះការដឹកជញ្ជូន

- ២២ មេសា ១៩៨៩ អនុក្រឹត្យលេខ២៥អនក្រ ស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនដល់ពលរដ្ឋកម្ពុជា

# ឯកជនភាវូបនីយកម្មនៃដីធ្លីនៅឆ្នាំ១៩៨៩ (២)

- ០៣ មិថុនា ១៩៨៩ សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, សេចក្តីណែនាំលេខ០៣សណន

  -កម្មសិទ្ធិលើដីសម្រាប់សង់លំនៅឋាន មានទំហំមិនលើសពី២០០០ម២

  -ភោគៈលើដីស្រែ ឬចម្ការ មានទំហំមិនលើសពី៥ហិកតា

  -សម្បទានលើដីសម្រាប់ដាំដុះដំណាំសំខាន់ៗ មានទំហំលើសពី៥ហិកតា

- ១៤ មិថុនា ១៩៨៩ នាយកដ្ឋានសុរិយោដី ត្រូវបានបង្កើតឡើង ដោយគ្រាន់តែផ្ទេរឈ្មោះពីនាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម

# ឯកជនភាវូបនីយកម្មនៃដីធ្លីនៅឆ្នាំ១៩៨៩ (៣)

- ១៣ តុលា ១៩៩២ ច្បាប់ភូមិបាលត្រូវបានប្រកាសឱ្យប្រើ (ច្បាប់ភូមិបាលឆ្នាំ១៩៩២)

-សិទ្ធិកម្មសិទ្ធិលើដីសម្រាប់សង់លំនៅឋាន (ម. ១៩)

-សិទ្ធិភោគៈ (មិនបានថែងជាដីប្រភេទណាទេ) (ម. ៦១-៧៦)

-កម្មសិទ្ធិអចលនវត្ថុ ចុះក្នុងសៀវភៅចុះកម្មសិទ្ធិអចលនវត្ថុ (ម. ២០៥)

-ភោគៈអចលនវត្ថុ ចុះក្នុងសៀវភៅចុះភោគៈអចលនវត្ថុ (ម. ២០៧)

-តាមការអនុវត្ត គេប្រើប្រាស់តែសៀវភៅចុះបញ្ជីអចលនវត្ថុតែប៉ុណ្ណោះ ប៉ុន្តែសិទ្ធិទាំងពីរខាងលើចុះក្នុង សៀវភៅដាច់ដោយឡែកពីគ្នា។ (ម. ២១៤)

-មិនបានថែងពីការចុះបញ្ជីដីរដ្ឋ។

# ឯកជនភាវូបនីយកម្មនៃដីធ្លីនៅឆ្នាំ១៩៨៩ (៤)

- **ការកើនចំនួនទំនាស់ដីធ្លីមិនអាចទប់ស្កាត់បាន**

  -កង្វះខាតប្រសិទ្ធភាពគ្រប់គ្រងដីធ្លី

  -ការរំលោភយកដីធ្លីពីសំណាក់អ្នកមានអំណាច អ្នកមានលុយ និងក្រុមហ៊ុន

  -អាជ្ញាមានសមត្ថកិច្ចពាក់ព័ន្ធនឹងដីធ្លីនៅមានភាពទន់ខ្សោយ

  -ច្បាប់ភូមិបាលឆ្នាំ១៩៩២នៅមានភាពខ្វះចន្លោះច្រើន និងមិនស្របតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

- **ច្បាប់ភូមិបាលថ្មីមួយទៀតត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០១ (ច្បាប់ភូមិបាលឆ្នាំ២០០១)**

  -ផ្តល់ជូនកម្មសិទ្ធិដល់ពលរដ្ឋកម្ពុជា

  -បញ្ចប់ការចូលកាន់កាប់ភោគៈ

# សកម្មភាព២

ហេតុអ្វីបានជារដ្ឋត្រូវបង្កើតឱ្យមានឯកជនភាវូបនីយកម្មដីធ្លីនៅឆ្នាំ១៩៨៩?

# គោលដៅនៃការគ្រប់គ្រងដីធ្លី (១)

- ច្បាប់ភូមិបាលឆ្នាំ២០០១ ធានាការពារសិទ្ធិកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុ

  -បង្កើតប្រព័ន្ធចុះបញ្ជីដីធ្លីដែលអាចជឿជាក់បាន

  -សុវត្ថិភាពនៃការកាន់កាប់ដីធ្លី

  -លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

  -ជំរុញការវិនិយោគលើដីធ្លី

  -បង្កើនចំណូលរបស់រដ្ឋតាមរយៈការបង្កើតពន្ធប្រថាប់ត្រាលើអចលនវត្ថុ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ការចេញប័ណ្ណ

  -ទប់ស្កាត់ការរំលោភដីធ្លី

# គោលដៅនៃការគ្រប់គ្រងដីធ្លី (២)

- អភិវឌ្ឍប្រកបដោយនិរន្តរភាពផ្នែកបរិស្ថាន និងសុខុដុមនីយកម្ម

-អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច, លេខ១៩អនក្រ/បក/១៩ មីនា ២០០៣ (បែងចែកដីធ្លីប្រកបដោយសមធម៌ និងស្មើភាពដល់ពលរដ្ឋក្រីក្រគ្មានដីធ្លី)

-អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨អនក្រ/បក/០៧ តុលា ២០០៥ (គ្រប់គ្រង និងការពារដីរដ្ឋប្រកបដោយប្រសិទ្ធភាព ដើម្បីងាយស្រួលក្នុងការអភិវឌ្ឍ)

-អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច, លេខ១៤៦អនក្រ/បក/២៧ ធ្នូ ២០០៥ (អភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងការពារផលប៉ះពាល់ដល់បរិស្ថាន)

# សកម្មភាព៣

ដើម្បីគ្រប់គ្រងដីធ្លីឱ្យមានប្រសិទ្ធភាព តើរដ្ឋគួរធ្វើដូចម្ដេចខ្លះ?

# នានាភាពនៃបញ្ហាអំពីដីធ្លី និងយន្តការដោះស្រាយ (១)

- **ការរំលោភយកដីធ្លីដែលមិនអាចទប់ស្កាត់បាន**

  -រវាងអ្នកមានអំណាច និងប្រជាពលរដ្ឋ

  -រវាងអ្នកមាន និងប្រជាពលរដ្ឋ

  -រវាងក្រុមហ៊ុន និងប្រជាពលរដ្ឋ

- **ទំនាស់ដីធ្លីបានកើនឡើងគួរឱ្យកត់សម្គាល់**

  -យន្តការដោះស្រាយទំនាស់មានភាពចាំបាច់

  -ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លីត្រូវការជាចាំបាច់

# នានាភាពនៃបញ្ហាអំពីដីធ្លី និងយន្តការដោះស្រាយ (២)

- **យន្តការដោះស្រាយទំនាស់ដីធ្លី**

  -គណៈកម្មការដោះស្រាយបាតុភាពដីធ្លី (១៩៩៩)

  -គណៈកម្មការសុរិយោដី (២០០២) ⟶ ដោះស្រាយទំនាស់ដីធ្លីដែលមិនមានប័ណ្ណ

  -អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (២០០៦)

- **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លីសំខាន់មួយចំនួន**

  -ច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវបានរំពឹងថានឹងអាចដោះស្រាយបញ្ហាដីធ្លីបានមួយចំនួនធំ

  -អនុក្រឹត្យស្តីពីការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ៤៦អនក្រ/បក/៣១ ឧសភា ២០០២

  -អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ៤៨អនក្រ/បក/៣១ ឧសភា ២០០២

# នានាភាពនៃបញ្ហាអំពីដីធ្លី និងយន្តការដោះស្រាយ (៣)

- បញ្ហានៃការអភិវឌ្ឍ

-សម្បទានដីសេដ្ឋកិច្ច

+ការសិក្សាពីផលប៉ះពាល់នៅមានកម្រិត

+ប្រជាពលរដ្ឋភាគច្រើនគ្មានប័ណ្ណកម្មសិទ្ធិ ឬប័ណ្ណភោគៈ

+ការចុះបញ្ជីដីធ្លីមិនទាន់បានធ្វើរួចរាល់ទូទាំងប្រទេស

+ទំហំដីកំណត់ក្នុងសម្បទានដីសេដ្ឋកិច្ចមិនមានភាពសុក្រឹត

-គម្រោងអភិវឌ្ឍមួយចំនួនមិនមានភាពច្បាស់លាស់ និងមិនអាចអនុវត្តបាន

# សកម្មភាព៤

តាមយោបល់របស់អ្នក តើត្រូវធ្វើដូចម្តេចដើម្បីកាត់បន្ថយវិវាទដីធ្លី?

# សេចក្តីសន្និដ្ឋាន

- **ការកាន់កាប់ដីធ្លីនៅកម្ពុជានៅមិនទាន់មានសុវត្ថិភាពទាំងស្រុងទេ**

  -ប្រព័ន្ធច្បាប់នៅខ្សោយ

  -ឆន្ទៈនយោបាយជាកត្តាសំខាន់ក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រងដីធ្លី

  -ចំណូលរដ្ឋបានមកពីដីធ្លីមិនទាន់ត្រូវបានពង្រឹង

- **ភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់មន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធនៅមានកម្រិត**

  -ការចេញប័ណ្ណដោយខុសឆ្គងមិនត្រូវបានចាត់វិធានការរដ្ឋបាលជាក់លាក់ដើម្បីពិន័យ

  -ការយល់ដឹងរបស់មន្ត្រីស៊ុរិយោដីនៅមានកម្រិត

## ឯកសារយោង

-ច្បាប់ភូមិបាលឆ្នាំ១៩៩២, លេខ១០០ក្រ/១៣ តុលា ១៩៩២។

-ច្បាប់ភូមិបាលឆ្នាំ២០០១, លេខ នស/រកម/០៨០១/១៤/៣០ សីហា ២០០១។

-Matthew Rendall et al., *ច្បាប់ភូមិបាលកម្ពុជា-សៀវភៅសិក្សា និងស្រាវជ្រាវ* (ភ្នំពេញ East-West Management Institute, Inc., ខែវិច្ឆិកា ឆ្នាំ២០០៣)។

-លីម វ៉ាន់, "របបដីធ្លីនៅកម្ពុជា,ខែកក្កដា ឆ្នាំ២០០៦," ឯកសារវាយកុំព្យូទ័រ (ឯកសារថតចម្លង)។

-គណៈកម្មការសុរិយោដី, *ជំនួយស្មារតីអំពីបញ្ហាដីធ្លី,* អ៊ឹម ឈុនលឹម, ប្រធាន (ភ្នំពេញ គណៈកម្មការសុរិយោដី, ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៦)។

-សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅ ឆ្នាំ២០០១ ដល់២០០៨ (ភ្នំពេញ សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)។

# សូមអរគុណ!

## សំណួរ និងចម្លើយ